ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និងឈ្មោះសំណុំរឿង : ១១៥/០៩-វ៉ាយអូឡែត

កាលបរិច្ឆេទនៃសេចក្តីសម្រេច : ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩

# សេចក្តីសម្រេចអាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៧នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លៈ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន វ៉ាយអូឡែត

អាសយដ្ឋាន : អគារ ១ អា ផ្លូវ២៧១ សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩១៦ ២៨៨ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

- លោក សុត កែវ រដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហព័ន្ធសហជីព-សហជីពយុវជនខ្មែរ ប្រចាំរោងចក្រ វ៉ាយអូឡែត

អាសយដ្ឋាន : អគារ ១ អា ផ្លូវ២៧១ សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១៧ ៤៣០ ៣១២ ទូរសារលេខ : គ្មាន

តំណាងកម្មករនិយោជិត : **អវត្តមាន**



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

## បញ្ហាវិវាទ

( នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា )

១- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់បន្ថែមចំនួន ៥ ដុល្លារ ជូនកម្មករនិយោជិត ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ គឺសុំអនុវត្តតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០ ។

២- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនតម្លើងប្រាក់អតីតភាព សម្រាប់កម្មករមានអតីតភាពការងារលើសពី ៤ ឆ្នាំ បូកបន្ថែម ១ ដុល្លារ ទៀត ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារនេះបានទេ ដោយសុំអនុវត្តតាមសេចក្តីជូនដំណឹងលេខ ០១៧ ស.ក.ប.យ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ។

៣- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ភាគកម្មក្នុងប្រាក់ចំណេញ ជូនកម្មករ និងសុំគិតសងឡើងវិញក្នុងរយៈពេលកន្លងមក ដែលក្រុមហ៊ុនពុំបានផ្តល់ជូន ។ ដោយឡែកភាគីក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ជូននូវប្រាក់ភាគកម្មក្នុងប្រាក់ចំណេញជូនកម្មករនិយោជិតបានទេ ។

៤- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានការពិនិត្យសុខភាពជាពិសេស ដល់កម្មករនិយោជិតទាំងអស់ ដោយនិយោជកជាអ្នកទទួលបន្ទុកចេញសោហ៊ុយ ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនចំពោះការស្នើសុំរបស់កម្មករនិយោជិតនេះបានទេ ។

៥- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនរៀបចំទារកដ្ឋានឱ្យបានសមស្របតាមប្រកាសរបស់ក្រសួង ។ ដោយឡែក ភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ ប៉ុន្តែក្រុមហ៊ុនបានផ្តល់សមស្របចំពោះស្ត្រីដែលយកកូនមកធ្វើរួចហើយ ។

៦- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនកុំកាត់ប្រាក់លើកទឹកចិត្តដែលធ្លាប់ទទួលបានពីមុន និងសុំសងវិលើកឡើងវិញ ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ ករណីមានការផ្តល់ជូនក្រុមហ៊ុននឹងពិនិត្យទៅលើភាពជាក់ស្តែង ព្រោះប្រាក់នេះ គឺជាប្រាក់រង្វាន់លើកទឹកចិត្ត ។

## សំអាងយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបំណងកិច្ចក្នុងការចេញសេចក្តីសម្រេចនេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីពីការមិនសះជា លេខ ៧៨៥ ក.ប/អក/វ.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្ដាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៤:០០ នាទី រសៀល (ភាគីសហជីព និង កម្មករនិយោជិត អវត្តមាន) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ៤៤២ សសយខ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ស្ដីពីការទាមទារឱ្យក្រុមហ៊ុនកែលំអរលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់មកនាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ១០ ចំណុច នៅសល់ចំនួន ០៦ចំណុចនេះ។ ចំណុចមិនសះជាចំនួន ០៦ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជា លេខ ៧៨៥ ក.ប/អក/វ.ក ចុះថ្ងៃទី២៤ ខែ សីហា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត ប្រចាំរោងចក្រ មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៤:០០ នាទី រសៀល។ ប៉ុន្តែ ភាគីសហជីពយុវជនខ្មែរ មិនបានមកចូលរួមសវនាការ ហើយក៏មិនបានស្នើសុំជាលាយល័ក្ខណ៍អក្សរ និងបញ្ជាក់ពីមូលហេតុដើម្បីពន្យារពេលសវនាការដែរ។ ដល់ម៉ោងបើកសវនាការ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទូរស័ព្ទលើកទៅភាគីសហជីព ពេលនោះភាគីសហជីព បានឆ្លើយតបមកលេខាធិការក្រុមប្រឹក្សាអាជ្ញាកណ្ដាលថា ពួកគាត់មិនមកចូលរួមសវនាការទេ ហើយសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលដំណើរការ តាមនីតិវិធីចុះ។ ចំណែកឯភាគីនិយោជកវិញ បានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលអនុវត្តតាមច្បាប់។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះ ដូចខាងក្រោម:

THE ARBITRATION COUNCIL

## អង្គនាង

## សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ឧត្តរាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក-ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធរបស់ក្រុមហ៊ុន ជូនលោក សុត កែវ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩។

២- លិខិតរបស់ក្រុមហ៊ុន គោរពជូនប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសូមពន្យាពេលបើកសវនាការ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយអរប្ញូឡែត លេខ ៧៨៥ ក.ប/អក/វ.ក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន វ៉ាយអរប្ញូឡែត ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៩៣ កប/អក/លកអ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៩៤ កប/អក/លកអ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។

## អង្គហេតុ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនេះទេ ដោយហេតុថា ភាគីសហជីពយុវជនខ្មែរ អវត្តមាននៅថ្ងៃសវនាការ។

## ហេតុផលនៃសេចក្តីសម្រេច

នៅក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត បានទទួលលិខិតអញ្ជើញឱ្យមកចូលរួមក្នុងសវនាការត្រឹមត្រូវ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយសម្រេចចិត្តមិនមកចូលរួមសវនាការ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លើសពីនេះទៀត ដល់ថ្ងៃសវនាការថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៤:០០ នាទី រសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទរំលឹកអំពីការមកចូលរួមសវនាការ។ ពេលនោះ ភាគីសហជីព កម្មករនិយោជិត បានឆ្លើយតបមកលេខាធិការក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ពួកគាត់មិនមកចូលរួម

សវនាការទេ ហើយសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលដំណើរការតាមនីតិវិធីចុះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម:

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬ មិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្ដាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្ដាល មុនពេលធ្វើសេចក្ដីសម្រេចរបស់ខ្លួន"*។

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬ អាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់"*។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតិ៍ លេខ ២៧/០៧-រ៉ូម និង វ៉ី ៣ លេខ ៩៥/០៨-យ៉ុង វ៉ា ទី ១ លេខ ១៣២/០៨-ជី អេច ជី និងលេខ ១៣៨/០៨-ម៉ាលើន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចបិទសំណុំរឿងបាន *"លក្ខខណ្ឌទី១: ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២: ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣: ភាគីមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន"*។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាលដែលបានសម្រេចបិទសំណុំរឿង នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬ ទេ?

**លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងត្រឹមត្រូវ**

ដោយផ្អែកលើចំណុច (ឃ) ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើលិខិតអញ្ជើញភាគីសហជីព កម្មករនិយោជិត ឱ្យមកចូលរួមសវនាការ ហើយមុនពេលសវនាការ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក៏បានទូរស័ព្ទរំលឹកដល់ភាគីសហជីព និងកម្មករនិយោជិត ដើម្បីមកចូលរួមសវនាការឱ្យទាន់តាមពេលវេលាកំណត់។ ប៉ុន្តែ ភាគីសហជីព និងកម្មករនិយោជិតបានឆ្លើយតបថា មិនមកចូលរួមសវនាការទេ ទោះបីជាទទួលបានដំណឹងអំពីកាលបរិច្ឆេទសវនាការពេលវេលា និងទីកន្លែងសវនាការរួចហើយ ស្របតាមវិធាន ៤.៧ ដែលជាឧបសម្ព័ន្ធ

THE ARBITRATION COUNCIL

នៃប្រកាស ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ដោយ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិត ពិតជាបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសវនាការប្រាកដមែន ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។ **ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ ។**

**លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា "ពាក្យបង្ហាញខ្លួនក្នុងសវនាការ" ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្ដាលរហូតចប់សព្វគ្រប់ ។

ដំណើរការអាជ្ញាកណ្ដាលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលផ្សះផ្សាឡើងវិញ

ឃ- និងដំណាក់កាលសវនាការដល់អង្គសេចក្ដី ។

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅក្នុងសវនាការតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។**

**លក្ខខណ្ឌទី៣ : ភាគីមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានផ្ដល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ ពីព្រោះមកដល់ថ្ងៃសវនាការ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ១៤:០០ នាទីរសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើទំនាក់ទំនងតាមទូរស័ព្ទរំលឹក ទៅភាគីនិយោជក និងភាគីសហជីព កម្មករនិយោជិត ស្រាប់តែភាគីសហជីព កម្មករនិយោជិតបានឆ្លើយតបថា ពួកគាត់មិនមកចូលរួមសវនាការទេ ហើយសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលដំណើរការតាមនីតិវិធីចុះ ។ ចំណែកឯ ភាគីក្រុមហ៊ុនបានអញ្ជើញមកចូលរួមក្នុងសវនាការ តាមកាលកំណត់ និងបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលអនុវត្តតាមច្បាប់ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា **ភាគីសហជីពយុវជនខ្មែរ មិនបានផ្ដល់មូលហេតុ ត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ ។**

ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីភាគីសហជីព និងកម្មករនិយោជិត មិនចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលមាន អំណាចក្នុងការចេញសេចក្តីបង្គាប់ដែរ ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់ សហជីពយុវជនខ្មែរប្រចាំរោងចក្រ វ៉ាយអូឡែត ដែលជាភាគីដើមបណ្តឹង ក្នុងការធ្វើការការពារចំពោះការទាមទារ របស់កម្មករនិយោជិត ដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ ។ ប៉ុន្តែ ភាគីសហជីព បានជ្រើសរើសការមិន ចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ ។ ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹង របស់ខ្លួន ប៉ុន្តែ ក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវ ហេតុផល និងភស្តុតាងដើម្បីការពារបណ្តឹងរបស់ខ្លួនទេ ។ ក្នុងករណី ភាគីដើមបណ្តឹងមិន ចូលរួមក្នុងសវនាការ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន ។ ការ សម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយស្មោះត្រង់របស់ភាគីសហជីព និងកម្មករនិយោជិតក្នុងការយក វិវាទការងាររបស់ខ្លួន មកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿងលេខ ១១៥/០៩-វ៉ាយអូឡែត នេះ ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សា អាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

- សម្រេចបិទសំណុំរឿងលេខ ១១៥/០៩-វ៉ាយអូឡែត ។

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : ម៉ែន សំអូនណា

ហត្ថលេខា: ..............................

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : អាន វីរៈ

ហត្ថលេខា: ..............................

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : គង់ ផល្លះ

ហត្ថលេខា: ..........